ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

លេខ: ០០២ ស.ណ.អ.ជ.ប.ត.ញ

ថ្ងៃចន្ទ ១០កើត ខែភទ្របទ ឆ្នាំឆ្លាមបញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ តុលា ឆ្នាំ២០២៣

គោលការណ៍ណែនាំ
សម្រាប់ចាត់តាំងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

និន្នាការនៃការផលិត ការចរាចរ ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅតែមានកំណើនខ្លាំងទាំងនៅក្នុងក្របខ័ណ្ឌអន្តរជាតិ តំបន់ និងអនុតំបន់ ហើយបានបន្តគំរាមកំហែង និងជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់ព្រះរាជាណាចក្រកម្ពុជា។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់គ្រឿងញៀនក្នុងស្រទាប់យុវវ័យបានរាលដាលគួរឱ្យព្រួយបារម្ភ បង្កជាផលប៉ះពាល់ដល់សុខភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ នាំឱ្យមានក្តីកង្វល់យ៉ាងខ្លាំងដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងសង្គមជាតិទាំងមូល។ ជាមួយនេះ ការកែច្នៃផលិតគ្រឿងញៀនខុសច្បាប់ត្រូវបានរកឃើញ និងបង្ក្រាបបានជាបន្តបន្ទាប់ ជាមួយនឹងវត្ថុមានសារធាតុគីមីផ្សំជាច្រើនត្រូវបានរកឃើញនៅទីតាំងទាំងនោះ។

ឆ្លើយតបទៅនឹងសភាពការណ៍ ក៏ដូចជាបញ្ហាខាងលើ និងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយអនុលោមតាមស្មារតីនៃកិច្ចប្រជុំលើកដំបូង របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ នៅទីស្តីការគណៈរដ្ឋមន្ត្រី និងគោរពអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ប្រកបដោយឆន្ទៈមុតស្រួច របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីដោះស្រាយទុក្ខកង្វល់របស់ប្រជាពលរដ្ឋ ធានាបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់ សន្តិសុខ និងការអភិវឌ្ឍន៍សង្គម ព្រមទាំងឈានទៅកាត់បន្ថយ និងលុបបំបាត់គ្រឿងញៀនពីកម្ពុជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមដាក់ចេញនូវគោលការណ៍ណែនាំ សម្រាប់ចាត់តាំងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនដូចខាងក្រោម៖

១. ការងារផ្សព្វផ្សាយអប់រំ៖

- គ្រប់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិទាំងអស់ ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយពីផលវិបាក និងគ្រោះថ្នាក់នៃគ្រឿងញៀន ឥទ្ធិពលនៃគ្រឿងញៀន និងអប់រំដាស់តឿនក្រើនរំលឹកដល់មន្ត្រីរបស់ខ្លួនគ្រប់ជាន់ថ្នាក់ឲ្យចៀសឆ្ងាយពីគ្រឿងញៀន
- បង្កើនការផ្សព្វផ្សាយពីសារអប់រំទាក់ទងនឹងគ្រឿងញៀន តាមរយៈបណ្តាញសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ទូរស័ព្ទចល័ត ប្រព័ន្ធទំនាក់ទំនងសង្គមនានា បដា ប៉ាណូ កាសែត ខិត្តប័ណ្ណ ក្តែយបត្រ ប្រើប្រាស់ទឹក ក្តែយបត្រប្រើប្រាស់អគ្គិសនី លើផលិតផលផ្សេងៗ

អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.ត.ញ ហានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

- បញ្ចូលប្រធានបទពាក់ព័ន្ធនឹងគ្រឿងញៀន ក្នុងកម្មវិធីសិក្សា និងវិញ្ញាសាប្រឡង
- សហការផលិតបទចម្រៀងអប់រំ រឿងអប់រំខ្លីៗ ខ្សែជីវិតពិតពីអ្នកញៀន និងផលវិបាករបស់ក្រុមគ្រួសារ ដើម្បីជាសារចែករំលែកដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់បានឃើញពីវិនាសកម្មដោយសារគ្រឿងញៀន
- កៀរគរសិល្បករ សិល្បការិនី និងតារាល្បីៗឲ្យជួយផ្សព្វផ្សាយសារអប់រំពីគ្រឿងញៀន នៅរាល់កម្មវិធីសម្តែងនានាគ្រប់ទម្រង់
- កៀរគរ ជំរុញឱ្យវិស័យឯកជន វិស័យសាសនា បន្តបង្កើនសកម្មភាពជួយផ្សព្វផ្សាយសារអប់រំពីគ្រឿងញៀនដល់បុគ្គលិក អតិថិជនរបស់ខ្លួន និងពុទ្ធបរិស័ទ គ្រីស្ទបរិស័ទកម្ពុជា សាសនិកឥស្លាមកម្ពុជា
- បង្កើតកម្មវិធីប្រឡងតែងកំណាព្យ គូរគំនូរ ឬអត្ថបទនិពន្ធនានា ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំសិក្ខាសាលា វេទិកានានា ផ្សព្វផ្សាយឲ្យទូលាយពីផលប៉ះពាល់ និងវិធានការសមស្របចំពោះមុខក្នុងការទប់ស្កាត់គ្រឿងញៀន
- បញ្ជ្រាបការអប់រំ តាមរយៈ ព្រះសង្ឃ អាចារ្យ ព្រឹទ្ធាចារ្យ ក្នុងកម្មវិធីសាសនា និងប្រពៃណីនៅតាមទីវត្តអារាម
- ជំរុញការលេងកីឡាគ្រប់ប្រភេទ ក្រោមប្រធានបទ កីឡាដើម្បីសុខភាពចៀសឆ្ងាយពីគ្រឿងញៀន
- កំណត់ក្រុមគោលដៅដែលត្រូវទទួលការអប់រំផ្សព្វផ្សាយ ដូចជា យុវជនគេចសាលា កម្មករ កម្ម-ការិនីក្នុងវិស័យកាត់ដេរ ស្បែកជើង រោងចក្រនានា សំណង់ អ្នកបើកបរ អ្នកធ្វើការពេលយប់ អ្នកបម្រើសេវាកម្សាន្តសប្បាយ ម្ចាស់សប្បាយដ្ឋាន ភ្ជួបកម្សាន្ត ភោជនីយដ្ឋាន សណ្ឋាគារ ខុនដូ ផ្ទះសំណាក់ បន្ទប់ជួល ឧទ្យានុក្រម
- បង្កើនការផ្សព្វផ្សាយ ពីទីតាំងព្យាបាលនៅតាមមូលដ្ឋានសេវាសុខាភិបាលសាធារណៈ និងទីតាំងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងមណ្ឌលគ្រប់គ្រងដោយរដ្ឋនិងឯកជន ដើម្បីឱ្យប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធបានដឹង និងស្គាល់។

២. ការបង្កើតយន្តការគ្រប់គ្រងសារធាតុគីមីផ្សំ៖

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រងសារធាតុគីមីនាំចូលទាំងឡាយណា ដែលអាចយកមកកែច្នៃផលិតជាសារធាតុញៀនបាន
- បង្កើតជាយន្តការថ្នាក់ជាតិមួយ ដើម្បីគ្រប់គ្រងសារធាតុគីមីផ្សំ ដែលអាចបង្វែរទៅផលិតជាគ្រឿងញៀនបាន
- រាល់ការប្រើប្រាស់ ក្សោទុក ដឹកជញ្ជូន ជួញដូរ សន្និធិ សារធាតុគីមីទាំងអស់ ត្រូវត្រួតពិនិត្យឱ្យបានច្បាស់លាស់។

៣. ការទប់ស្កាត់ការនាំចូលគ្រឿងញៀន៖

- បង្កើនការយកចិត្តទុកដាក់ ការត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ជាពិសេសនៅក្បែរតំបន់ត្រីកោណមាស បន្ថែមឧបករណ៍សម្គាល់បច្ចេកទេស ម៉ាស៊ីនស្កែន សុនខហិតក្លិនជាដើម
- ពង្រឹងសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន ទប់ស្កាត់ការនាំគ្រឿងញៀនចូលឧសច្បាប់តាមច្រករបៀងច្រកទ្វេភាគី ច្រកទ្វារតំបន់
- បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ សហការជាមួយភាគីមិត្ត ផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការនាំគ្រឿងញៀនឆ្លងដែន ដើម្បីទប់ស្កាត់ បង្ក្រាបឲ្យបានទាន់ពេលវេលា
- យកចិត្តទុកដាក់លើការនាំគ្រឿងញៀនតាមផ្លូវទឹក លំហសមុទ្រ និងកំពង់ផែអន្តរជាតិ
- បង្កើនការត្រួតពិនិត្យលើបញ្ហីប្រៃសណីយ៍ពីបរទេស និងចេញទៅក្រៅប្រទេស
- ពង្រឹងនិងលើកកម្ពស់សមត្ថភាពជាប្រចាំ ជូនដល់មន្ត្រីនៃកងកម្លាំងមានសមត្ថកិច្ចនៅគ្រប់ច្រក។

៤. ការទប់ស្កាត់ការកែច្នៃផលិតគ្រឿងញៀន៖

- គ្រប់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងត្រួតពិនិត្យឃ្លាំង ឬចង្វាក់ផលិតកម្មផ្សេងៗ ត្រូវធ្វើបច្ចុប្បន្នភាព និងតាមដានឲ្យបានជិតដល់ ដោយស្មារតីទទួលខុសត្រូវចៀសវាងកុំឱ្យឧក្រិដ្ឋជនឆ្លៀតប្រើប្រាស់ទីតាំងទាំងនោះ: លួចលាក់កែច្នៃផលិតសារធាតុញៀន
- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់ពិនិត្យ ឃ្លាំមើល រកទីតាំងសង្ស័យទាំងឡាយណាដែលអាចប្រើប្រាស់ជាកន្លែងកែច្នៃផលិតសារធាតុញៀន ដូចជា ឃ្លាំងឬកសិដ្ឋានដាច់ស្រយាល នៅក្បែរតំបន់ព្រៃ ភ្នំ ។ល។
- មន្ទីរពិសោធន៍គ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អ.ជ.ត.ប.ញ. ត្រូវរៀបចំចងក្រងជាមេរៀនពិសោធមួយ អំពីលក្ខណៈ និងស្ថានភាពដែលអាចសង្ស័យជាទីតាំងផលិតគ្រឿងញៀន (ដូចជា ក្លិន ផ្សែង សារធាតុគីមី ការចរាចរដ៏កម្រិតចេញចូលឧសប្រក្រតី ស្មៅរុក្ខជាតិនៅក្បែរក្រៀមងាប់ សត្វមិនហ៊ាននៅក្បែរ មានកាកសំណល់រាវពុលហូរចេញ ។ល។) ដើម្បីចែករំលែកឲ្យអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងប្រជាពលរដ្ឋទូទៅ យល់ដឹង និងរាយការណ៍ជូនសមត្ថកិច្ច ពេលឃើញទីតាំងសង្ស័យ។

៥. ការលុបបំបាត់ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀន៖

- គណៈបញ្ជាការឯកភាពរាជធានី-ខេត្ត លុបបំបាត់ការប្រើប្រាស់ និងជួញដូរគ្រឿងញៀននៅក្នុងមូលដ្ឋាន និងកន្លែងមិនទាន់រៀបរយផ្សេងៗ រួមទាំងក្នុងក្លឹបកម្សាន្ត ខុនដូ បារ KTV ផ្ទះសំណាក់ ។ល។ ដោយត្រូវគ្រប់គ្រងឲ្យបានម្ចាស់អាជីវកម្មពិតប្រាកដមានកិច្ចសន្យាច្បាស់លាស់ និងចាត់វិធានការបង្ក្រាបជាបន្ទាន់ពេលមានព័ត៌មាន អំពីការប្រើប្រាស់និងជួញដូរគ្រឿងញៀនក្នុងទីតាំងសប្បាយដ្ឋានទាំងនេះ
- បង្កើនការត្រួតពិនិត្យរដ្ឋបាលតាមគោលដៅសង្ស័យនានា
- អនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព គ្មានគ្រឿងញៀន ជំរុញអ្នកញៀន ចូលទៅកែការព្យាបាលនៅតាមមូលដ្ឋានសេវាសុខាភិបាលសាធារណៈ ឬមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលគ្រប់គ្រងដោយរដ្ឋ និងឯកជន

- ខិតខំលើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់ បណ្តុះបណ្តាលជំនាញ និងក្រមសីលធម៌ ឈានទៅទប់ស្កាត់រាល់អំពើពុករលួយ និងភាពអសកម្មពេលបង្ក្រាបករណីគ្រឿងញៀន
- ស្នើសុំស្ថាប័នតុលាការ ដាក់ទោសធ្ងន់ធ្ងរ និងទប់ស្កាត់ការដោះលែង ចំពោះឧក្រិដ្ឋជនគ្រឿងញៀន
- ត្រូវតាមដានការចូលរួមរាយការណ៍ពីប្រជាពលរដ្ឋ ដោយបច្ចុប្បន្ន អ.ជ.ប.ត.ញ. កំពុងរៀបចំតម្លើងប្រព័ន្ធhotline រាយការណ៍ពីករណីប្រើប្រាស់ ជួញដូរគ្រឿងញៀន ដោយរក្សាការសម្ងាត់ និងសុវត្ថិភាពជូនបុគ្គលរាយការណ៍
- យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពទិសស្លោក ៣ កុំ ១ រាយការណ៍ (កុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍)។

៦. អគ្គលេខាធិការដ្ឋាន នៃអ.ជ.ប.ត.ញ. ត្រូវរៀបចំចាត់តាំងក្រុមការងារដើម្បីត្រួតពិនិត្យ ជំរុញ តាមដាន និងសហការជួយសម្របសម្រួលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ឱ្យបានស្អិតរមួត និងស៊ីជម្រៅ ស្របតាមខ្លឹមសារក្នុងគោលការណ៍ណែនាំនេះ រួចធ្វើការ បូកសរុប វាយតម្លៃ និងធ្វើរបាយការណ៍ ពីលទ្ធផលជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងរាជរដ្ឋាភិបាល ដើម្បីមានមូលដ្ឋានពិចារណាតាមចក្ខុវិស័យ និងដាក់ចេញទិសដៅសម្រាប់អនុវត្តចំពោះមុខ។

ទទួលបានគោលការណ៍ណែនាំនេះ ខ្ញុំសូម ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេស-រដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នាយឧត្តមសេនីយ៍ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាអនុប្រធាន និងសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចាត់តាំងអនុវត្តការងារខាងលើទៅតាមជំនាញ និងវិស័យរបស់ខ្លួន ព្រមទាំងរៀបចំផែនការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបបានទៅនឹងសភាពការណ៍គ្រឿងញៀននៅក្នុងផែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សៀវ ឈួក

ចម្លងជូន៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អនុប្រធាន និងសមាជិក នៃអ.ជ.ប.ត.ញ.
- គណៈកម្មការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ